ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអគ្គនាយកដ្ឋាន គស្តុភារ និងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៧០៤ /១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកត / ០១៩៦ /០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ មកជាអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបង្កើតអគ្គនាយកដ្ឋានគស្តុភារ និងហិរញ្ញវត្ថុ ចំណុះក្រសួងមហាផ្ទៃ ។

មាត្រា២ : អគ្គនាយកដ្ឋានភស្តុភារ និង ហិរញ្ញវត្ថុ មានតួនាទីធ្វើជាសេនាធិការជូនក្រសួងមហាផ្ទៃ ក្នុងការដឹកនាំគ្រប់គ្រង ទ្រព្យសម្បត្តិ សំភារៈ ថវិកា មធ្យោបាយ និងកិច្ចលទ្ធកម្មសាធារណៈ ដែលស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ អោយត្រឹមត្រូវតាមច្បាប់កំណត់ ។

មាត្រា៣ : អគ្គនាយកដ្ឋានភស្តុភារ និង ហិរញ្ញវត្ថុ ដឹកនាំគ្រប់គ្រង ដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួនជាជំនួយការ ។

មាត្រា៤ : ត្រូវបានបំបែក នាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាយកដ្ឋានភស្តុភារ និងសម្ភារៈបច្ចេកទេស នាយកដ្ឋានស្ថាបនា ចេញពីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងអគ្គស្នងការដ្ឋាននគរបាលជាតិ ដោយត្រូវបានដាក់បញ្ចូលនៅចំណុះអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ វិញ ។

មាត្រា៥ : អគ្គនាយកដ្ឋានភស្តុភារ និង ហិរញ្ញវត្ថុ មានភារកិច្ចដូចខាងក្រោម :

-គ្រប់គ្រង ចំណូល-ចំណាយ ថវិកាជាតិ ដែលស្ថិតនៅក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃអោយបានត្រឹមត្រូវតាមច្បាប់កំណត់ ។

-គ្រប់គ្រងសំភារៈបច្ចេកទេស-មធ្យោបាយដឹកជញ្ជូន-មធ្យោបាយផ្សេងៗ សំរាប់បំរើសកម្មភាពការងារគ្រប់ប្រភេទរបស់ក្រសួងមហាផ្ទៃ ។

-គ្រប់គ្រងទ្រព្យសម្បត្តិ-អចលវត្ថុ ចលនៈវត្ថុទាំងឡាយរបស់រដ្ឋ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ ។

-ទទួលខុសត្រូវលើការអនុវត្តនីតិ កិច្ចលទ្ធកម្មសាធារណៈ អោយត្រឹមត្រូវតាមច្បាប់កំណត់ ។

-លើកគំរោងផែនការ ថវិកា មធ្យោបាយ សំភារៈ ប្រេងឥន្ធនៈ ស្បៀង សំរាប់ការផ្គត់ផ្គង់អោយដំណើរការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃប្រចាំឆ្នាំ ។

-គ្រប់គ្រងចំណូល បង់ចូលថវិកាជាតិស្របតាមច្បាប់កំណត់ ។

-ធ្វើការបែងចែកថវិកា និងផ្គត់ផ្គង់រាល់សំភារៈបរិក្ខា មធ្យោបាយនានា ជូនក្រសួងមហាផ្ទៃ ។

-បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា៦ : រចនាសម្ព័ន្ធ អគ្គនាយកដ្ឋាន ភស្តុភារ និងហិរញ្ញវត្ថុ រួមមាន :

-នាយកដ្ឋានភស្តុភារ និង សំភារៈបច្ចេកទេស

-នាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-នាយកដ្ឋានស្ថាបនា

-លេខាធិការដ្ឋាន

**មាត្រា៧:** តួនាទីភារកិច្ច និងរចនាសម្ព័ន្ធ របស់លេខាធិការដ្ឋាន នាយកដ្ឋាន និងការិយាល័យចំណុះត្រូវកំណត់ ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៨ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារ ផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៩
- ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋាន គស្តុភារ និងហិរញ្ញវត្ថុ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក

ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧

